# តើ ព្រះយេស៊ូវ ពិតជាបាន រស់ឡើងវិញ មែនឬ?

## ហេតុការណ៍ដែលគេដឹង

- សិស្សប្រកាសទៅហ្វូងមនុស្សនៅក្រុងយេរូសាឡិមថា ព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញមែន
- សិស្សដែលភ័យខ្លាចពីមុន ក៏ចាប់ផ្តើមប្រកាសពីការមានព្រះជន្មរស់ដោយចិត្តក្លាហាន
- ដោយសារជំនឿ ពួកសិស្សនិងសាវ័ក (ទាំង១១/១២) ត្រូវរងទណ្ឌកម្មហើយស្លាប់
- សាក្សីជាង៥០០នាក់អះអាងថា គេឃើញព្រះយេស៊ូវបន្ទាប់ពីទ្រង់បានរស់ឡើងវិញ
- គ្រីស្ទសាសនាបានរីករាលដាលយ៉ាងរហ័សនៅសម័យនោះ
- ព្រះយេស៊ូវត្រូវបានគេធ្វើទារុណកម្ម ហើយសម្លាប់ចោល
- គេមិនឃើញសពព្រះយេស៊ូវនៅក្នុងផ្នូរឡើយ



## ទ្រឹស្តីដែលគេលើកយកមកវាយប្រហារសេចក្តីពិត

### ទ្រឹស្តី

**១ សន្លប់**
តាមពិតព្រះយេស៊ូវមិនបានសុគតទេ ប៉ុន្តែទ្រង់គ្រាន់តែសន្លប់លើឈើឆ្កាង រួចមកក៏ដឹងខ្លួនឡើងវិញ។

**២ មមើមមាល**
សិស្សរបស់ព្រះយេស៊ូវឃើញទ្រង់ក្នុងក្តីមមើមមាលតែប៉ុណ្ណោះ។

**៣ វិញ្ញាណរស់ឡើងវិញ**
ការរស់ឡើងវិញរបស់ព្រះយេស៊ូវ គឺគ្រាន់តែរស់ខាងវិញ្ញាណ តែមិនមែនខាងសាច់ឈាមទេ។

**៤ មានគេលួចសព**
ពួកសាវ័កបានលួចសពរបស់ទ្រង់ ហើយនាំគ្នាអះអាងថា ទ្រង់បានរស់ឡើងវិញ។

**៥ គេច្រឡំផ្នូរ**
ដោយសារពួកសាវ័កកំពុងស្ថិតក្នុងការកាន់ទុក្ខ ដូច្នេះហើយបានជាពួកគេច្រឡំផ្នូរ ពេលពួកគេទៅរកទ្រង់។

### ការជំទាស់

- ពួកទាហានរ៉ូមដែលជាពួកអ្នកជំនាញខាងពេជ្ឈឃាដ គឺជាអ្នកមើលការខុសត្រូវលើការឆ្កាងព្រះយេស៊ូវ ហើយក៏ជាអ្នកអះអាងថា ទ្រង់ពិតជាបានសុគតមែន។
- តើទ្រង់អាចស្រាយក្រណាត់រុំសពដោយខ្លួនឯង រមៀលផ្ទាំងថ្ម វាយយកឈ្នះទាហាន ហើយដើរបានដល់ ១១ គីឡូម៉ែត្របានយ៉ាងដូចម្តេចទៅ បើគេទើបតែធ្វើទារុណកម្មទ្រង់ ឆ្កាងទ្រង់ យកលំពែងមកចាក់ទ្រង់ ហើយបញ្ចុះសពទ្រង់?
- ព្រះយេស៊ូវបានបើកសម្តែងអង្គទ្រង់ ក្រោយពីទ្រង់បានមានព្រះជន្មរស់ឡើងវិញដល់មនុស្សជាច្រើន ក៏ដូចជាហ្វូងមនុស្សជាច្រើនក្នុងកាលៈទេសៈខុសៗគ្នាជាច្រើនលើកច្រើនសារ។
- ពួកសិស្សដំបូងៗបានជឿថា ព្រះយេស៊ូវពិតជាបានមានព្រះជន្មរស់ឡើងវិញមែន ទោះបើមានមនុស្សជាច្រើនមិនជឿដូចពួកគេក៏ដោយ។
- កណ្ឌគម្ពីរដំណឹងល្អទាំងបួនជាកណ្ឌគម្ពីរបែបប្រវត្តិសាស្ត្រ មិនមែនជារឿងតំណាង ឬរឿងប្រៀបធៀបនោះឡើយ។
- ការដែលកណ្ឌគម្ពីរដំណឹងល្អទាំងបួនបានលើកឡើងពីការដែលព្រះយេស៊ូវបានសម្តែងរូបអង្គទ្រង់គ្រប់ទាំងកណ្ឌ នោះគឺជាអំណះអំណាងដ៏ពិត។ នេះជាចំណុចដ៏សំខាន់ទាក់ទងនឹងប្រវត្តិសាស្ត្រ។
- ការដែលសាសន៍យូដាចោទថា ពួកសិស្សបានលួចសពព្រះយេស៊ូវ បង្ហាញថានៅក្នុងផ្នូរគ្មានសព។ (ម៉ាថាយ ២៨:១៥)
- ដើម្បីឲ្យពួកសាវ័កអាចលួចសពទ្រង់បាន ពួកគេត្រូវមានផែនការយ៉ាងលម្អិត រួមទាំងការសូកប៉ាន់ពួកអ្នកយាម ក៏ដូចជាមានការជំរុញចិត្តឲ្យធ្វើជាខ្លាំង ហើយមានកន្លែងដើម្បីនឹងលាក់សព និងមានស្មរបន្ទាល់ក្លែងក្លាយ ហើយដាច់ខាតស្មរបន្ទាល់ទាំងនោះត្រូវលាក់អាថ៌កំបាំងរហូតដល់ថ្ងៃស្លាប់។
- រឿងនេះ វាសាមញ្ញ ហើយមានការខ្វះខាតក្នុងការបង្ហាញថា វាជារឿងច្នៃប្រឌិតដែលក្រោយមកក្លាយជារឿងព្រេង។
- បើព្រះយេស៊ូវគ្រាន់តែរស់ឡើងវិញខាងវិញ្ញាណ តើមានរឿងអ្វីកើតឡើងចំពោះព្រះកាយរបស់ទ្រង់?
- លក្ខណៈពេលដែលព្រះកាយជាសាច់ឈាមរបស់ព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញ ទ្រង់ក៏បានទទួលសិរីរុងរឿងដែរ៖ ទ្រង់នៅអាចសោយអាហារ ហើយយើងក៏អាចប៉ះទ្រង់បាន។
- សាវ័ក ប៉ុល បានអះអាងថា ជំនឿគ្រីស្ទបរិស័ទគ្មានប្រយោជន៍ឡើយ ប្រសិនព្រះយេស៊ូវមិនបានមានព្រះជន្មរស់ឡើងវិញខាងសាច់ឈាម។
- ពួកសិស្សបានឈឺចិត្តយ៉ាងខ្លាំងពីការដែលព្រះយេស៊ូវបានសុគត។
- តើពួកសិស្សពិតជាហានពលីជីវិតរបស់ខ្លួនទៅលើការកុហកដែលពួកគេបានច្នៃប្រឌិតមែនឬ?
- ការដែលថា ពួកសិស្សបានច្រឡំផ្នូរមានន័យថា ពួកគេបានបដិសេធទីបន្ទាល់របស់លោកយ៉ូសែប ដែលនៅភូមិអើរីម៉ាថេ ដែលគាត់ផ្ទាល់ជាអ្នកយកសពព្រះយេស៊ូវទៅបញ្ចុះក្នុងផ្នូរ។
- មានសាក្សីជាច្រើនដែលបានឃើញពីទីកន្លែងដែលគេបញ្ចុះសពព្រះយេស៊ូវ។
- ប្រសិនបើពួកសិស្សពិតជាបានទៅច្រឡំផ្នូរដោយអចេតនាមែន ដូច្នេះពួកគេគ្រាន់តែនាំគ្នាទៅផ្នូរដែលជាកន្លែងពិត នោះគេនឹងដឹងថា រឿងនោះពិត ឬមិនពិតហើយ។
- មិនមានភស្តុតាងណាមួយដែលអាចបញ្ជាក់ថា មានគេលួចសពព្រះយេស៊ូវឡើយ។
- សព្វថ្ងៃនេះ ពួកទេវវិទូស្ទើរគ្រប់គ្នាបានទទួលស្គាល់ថា ទ្រឹស្តីទាំងអស់នេះមិនត្រឹមត្រូវឡើយ។ គ្រប់ទាំងទ្រឹស្តីទាំងនេះ មិនអាចលើកយកមកអះអាងឈ្នះទៅនឹងទ្រឹស្តីដែលអះអាងថា ព្រះយេស៊ូវពិតជាមានព្រះជន្មរស់ឡើងវិញឡើយ។

## តើអ្វីទៅជាអំណះអំណាងដ៏ត្រឹមត្រូវបំផុតដែលបញ្ជាក់ថា ព្រះយេស៊ូវពិតជាមានព្រះជន្មរស់ឡើងវិញ?

# ចម្លើយ៖ ព្រះជាម្ចាស់បានប្រោសព្រះយេស៊ូវ ឲ្យមានព្រះជន្មរស់ឡើងវិញ!

ផ្លូវពិត
plovpit.com